ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ.......................................................

# សុន្ទរកថាបើក

## លោកជំទាវ នាង ច័ន្ទថាណា ទេសាភិបាលរងធនាគារជាតិនៃកម្ពុជា
## ថ្លែងក្នុងពិធីបើកសន្និសីទម៉ាក្រូសេដ្ឋកិច្ចប្រចាំឆ្នាំលើកទី២ ស្តីពី
## "ការអភិវឌ្ឍទីផ្សារហិរញ្ញវត្ថុ ដើម្បីរួមចំណែកលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល"
## នៅសណ្ឋាគារសូហ្វីតែល ភ្នំពេញ ភូគីតគ្រា ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៥

**សូមគោរព ៖**

**- ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាទីមេត្រី!**

ថ្ងៃនេះ ខ្ញុំមានសេចក្តីសោមនស្សរីករាយជាអនេក ដែលបានចូលរួមក្នុងសន្និសីទម៉ាក្រូសេដ្ឋកិច្ចប្រចាំឆ្នាំលើកទី២ របស់ធនាគារជាតិនៃកម្ពុជាប្រចាំឆ្នាំ២០១៥ ។ ខ្ញុំក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាតំណាងមកពីក្រសួង/ស្ថាប័នរបស់រាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ សភាពាណិជ្ជកម្ម គ្រឹះស្ថានឧត្តមសិក្សា វិទ្យាស្ថានស្រាវជ្រាវ និងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលបានឆ្លៀតឱកាសដ៏មានតម្លៃចូលរួមក្នុងសន្និសីទរបស់យើងនាពេលនេះ ។ នេះជាលើកទី២ហើយដែលសន្និសីទម៉ាក្រូសេដ្ឋកិច្ចធនាគារជាតិនៃកម្ពុជាត្រូវបានរៀបចំឡើង ក្នុងគោលបំណងរួមចំណែកពង្រឹងនិងអភិវឌ្ឍសមត្ថភាពស្រាវជ្រាវ និងផ្តល់ជាវេទិកាដល់អ្នករៀបចំគោលនយោបាយ សេដ្ឋវិទូ អ្នកស្រាវជ្រាវ និងនិស្សិត ដើម្បីពិភាក្សាផ្លាស់ប្តូរយោបល់និងបទពិសោធន៍ទៅលើប្រធានបទទាក់ទងនឹងបញ្ហាម៉ាក្រូសេដ្ឋកិច្ចសំខាន់ៗ ដែលអាចជាបញ្ហាប្រឈមដល់សេដ្ឋកិច្ច និងស្វែងរកដំណោះស្រាយសម្រាប់ជាធាតុចូលក្នុងការរៀបចំគោលនយោបាយសេដ្ឋកិច្ច សំដៅបន្តគាំទ្រកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព ។

កាលពីឆ្នាំ២០១៤ កន្លងទៅ ប្រធានបទនៃសន្និសីទរបស់យើងផ្តោតទៅលើ "ការពង្រឹងការផ្តល់ហិរញ្ញប្បទាននិងការរក្សាស្ថិរភាពហិរញ្ញវត្ថុនៅកម្ពុជា" ។ ខ្ញុំសូមវាយតម្លៃខ្ពស់ចំពោះការរួមចំណែកក្នុងការស្រាវជ្រាវនិងពិភាក្សាលើប្រធានបទដ៏សំខាន់នេះ ។ លទ្ធផល



ប្រអប់សំបុត្រលេខ ២៥, ផ្លូវលេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

ដែលទទួលបានពីសន្និសីទនេះត្រូវបានយកទៅបញ្ចូលក្នុងការរៀបចំ និងអនុវត្តគោលនយោបាយអភិវឌ្ឍវិស័យហិរញ្ញវត្ថុឱ្យកាន់តែរឹងមាំនិងស៊ីជម្រៅ សម្រាប់ភាគីពាក់ព័ន្ធទាំងវិស័យសាធារណៈ និងឯកជន ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ។

នៅក្នុងឆ្នាំនេះ ធនាគារជាតិនៃកម្ពុជាបានលើកយកប្រធានបទ "ការអភិវឌ្ឍទីផ្សារហិរញ្ញវត្ថុដើម្បីរួមចំណែកលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល" មកធ្វើជាប្រធានបទស្រាវជ្រាវ និងពិភាក្សា ដើម្បីបង្កើនការយល់ដឹងបន្ថែមពីតួនាទីរបស់ទីផ្សារហិរញ្ញវត្ថុ បញ្ហាប្រឈម និងដំណោះស្រាយក្នុងការលើកកម្ពស់ការប្រើប្រាស់រូបិយវត្ថុជាតិនិងសារៈសំខាន់របស់ការប្រើប្រាស់រូបិយវត្ថុជាតិក្នុងការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយចីរភាព តុល្យភាព និងបរិយាប័ន្ន ។ ការជ្រើសរើសប្រធានបទនេះធ្វើឡើងស្របពេលដែលរាជរដ្ឋាភិបាលកម្ពុជាបាននិងកំពុងយកចិត្តទុកដាក់កាន់តែខ្លាំង លើការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលនៅក្នុងសេដ្ឋកិច្ច ដូចដែលមានចែងក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ និងយុទ្ធសាស្ត្រអភិវឌ្ឍវិស័យហិរញ្ញវត្ថុ ២០១១-២០២០ ។ លើសពីនេះ រាជរដ្ឋាភិបាលនិងធនាគារជាតិនៃកម្ពុជាបានរៀបចំគោលនយោបាយ និងផែនការសកម្មភាពលើកកម្ពស់ប្រាក់រៀលដើម្បីបង្កើនការប្រើប្រាស់ប្រាក់រៀលឱ្យកាន់តែទូលំទូលាយនៅទូទាំងប្រទេស សំដៅកាត់បន្ថយដុល្លារូបនីយកម្មក្នុងរយៈពេលវែង ។ ផែនការនេះនឹងត្រូវបានអនុវត្តក្នុងពេលឆាប់ៗនេះ ។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី!**

ទាក់ទងនឹងប្រធានបទថ្ងៃនេះ ខ្ញុំសូមជម្រាបជូន ឯកឧត្តម លោកជំទាវ លោក លោកស្រី ពីប្រវត្តិសង្ខេបនិងស្ថានភាពនៃការប្រើប្រាស់រូបិយប័ណ្ណបរទេសក្នុងសេដ្ឋកិច្ចកម្ពុជា ដូចខាងក្រោម ៖

ដុល្លារូបនីយកម្មនៅកម្ពុជា កើតឡើងមិនមែនមកពីការសម្រេចរបស់រាជរដ្ឋាភិបាលទេ តែដោយសារកត្តាប្រវត្តិសាស្ត្រ ។ សង្គ្រាមស៊ីវិលដែលបានអូសបន្លាយជិត ៣ទសវត្សរ៍ ជាពិសេស ក្នុងរបប ប៉ុល ពត ដែលបានបំបាត់ទីផ្សារ រូបិយវត្ថុជាតិ និងអ្វីៗទាំងអស់របស់ប្រជាជនកម្ពុជា បានធ្វើឱ្យជំនឿទុកចិត្តរបស់ប្រជាជនមកលើប្រាក់រៀលបាត់បង់យ៉ាងខ្លាំង ទោះជាប្រាក់រៀលត្រូវបានបង្កើតឡើងវិញចាប់តាំងពីឆ្នាំ១៩៨០ ក៏ដោយ ។ នៅក្នុងបរិការណ៍ដែលប្រាក់រៀលត្រូវបានគេជឿទុកចិត្តតិចតួច នៅដើមទសវត្សរ៍ឆ្នាំ១៩៩០ ប្រាក់ដុល្លារបាន

ហូរចូលជាគំហុកមកក្នុងសេដ្ឋកិច្ចកម្ពុជាដែលមានទំហំតូចនិងមានភាពទន់ខ្សោយនៅឡើយ តាមរយៈការចំណាយរបស់ UNTAC ក្នុងប្រតិបត្តិការរក្សាសន្តិភាពនៅកម្ពុជា ។ ប្រាក់ដុល្លារដែលហូរចូលត្រូវបានយកមកប្រើប្រាស់ដោយផ្ទាល់នៅក្នុងសេដ្ឋកិច្ច ដោយគ្មាន ឬមានការប្តូរតិចតួចបំផុតជារូបិយវត្ថុជាតិ ។ លើសពីនេះ ការបើកចំហរសេដ្ឋកិច្ច និងការអនុវត្តប្រព័ន្ធសេដ្ឋកិច្ចទីផ្សារសេរី ដោយធ្វើសេរីភាវូបនីយកម្មលើការវិនិយោគនិងពាណិជ្ជកម្មបានជំរុញឱ្យកម្រិតដុល្លារូបនីយកម្មនៅកម្ពុជាកើនឡើងជាបន្តបន្ទាប់ ជាពិសេសតាមរយៈលំហូរចូលនៃវិនិយោគផ្ទាល់បរទេស ចំណូលពីការនាំចេញ ជំនួយបរទេស ចំណូលពីទេសចរណ៍ និងការផ្ទេរប្រាក់ពីបរទេស ជាដើម ។ ដុល្លារូបនីយកម្មនៅកម្ពុជាដែលវាស់ដោយអនុបាតប្រាក់បញ្ញើរូបិយប័ណ្ណធៀបនឹងរូបិយវត្ថុទូទៅ (FCD/M2) បានកើនឡើងពីប្រមាណ ៣៦% នៅឆ្នាំ១៩៩៣ ដល់ ៧០% នៅក្នុងឆ្នាំ២០០៣ ហើយបានបន្តកើនឡើងដល់ប្រមាណ ៨០% នៅក្នុងឆ្នាំ២០១៣ និងបន្តរក្សាក្នុងកម្រិតនេះរហូតដល់បច្ចុប្បន្ន ។

កន្លងមក សេដ្ឋកិច្ចកម្ពុជាបានទទួលអត្ថប្រយោជន៍ពីដុល្លារូបនីយកម្ម ដោយបានទាក់ទាញវិនិយោគបរទេសឱ្យកើនឡើងយ៉ាងឆាប់រហ័ស អភិវឌ្ឍវិស័យហិរញ្ញវត្ថុ និងជំរុញសមាហរណកម្មសេដ្ឋកិច្ចកម្ពុជាទៅក្នុងតំបន់និងសកល និងថែមទាំងបានចូលរួមទប់ស្កាត់វិបត្តិហិរញ្ញវត្ថុដែលបានកើតឡើងនៅអាស៊ីនៅឆ្នាំ១៩៩៧-១៩៩៨ មិនឱ្យចូលមកកម្ពុជាទៀតផង ។ ក៏ប៉ុន្តែ ដុល្លារូបនីយកម្មក៏បានធ្វើឱ្យសេដ្ឋកិច្ចកម្ពុជាប្រឈមនឹងហានិភ័យនិងមានភាពផុយស្រួយដែរ នៅពេលដែលទំហំសេដ្ឋកិច្ចនិងវិស័យហិរញ្ញវត្ថុកាន់តែមានកំណើនជាលំដាប់ ដូចជាការដាក់កំហិតលើការប្រើប្រាស់ឧបករណ៍និងប្រសិទ្ធភាពគោលនយោបាយរូបិយវត្ថុ ហានិភ័យពាក់ព័ន្ធនឹងការប្រែប្រួលអត្រាប្តូរប្រាក់ និងការរងឥទ្ធិពលពីការអនុវត្តគោលនយោបាយរូបិយវត្ថុរបស់សហរដ្ឋអាមេរិកជាដើម ។ ទាក់ទងនឹងចំណុចទាំងនេះ សន្និសីទយើងនឹងពិភាក្សាបន្ថែមនាពេលបន្តិចទៀតនេះ ។

ពិតមែនតែដុល្លារូបនីយកម្មជាបញ្ហាប្រឈមដ៏សំខាន់មួយចំពោះសេដ្ឋកិច្ចកម្ពុជាក៏ដោយ ការធ្វើបដិដុល្លារូបនីយកម្មភ្លាមៗដោយប្រើប្រាស់វិធានការរដ្ឋបាលមិនមែនជាជម្រើសដ៏ប្រសើរសម្រាប់កម្ពុជាទេ ដោយកម្ពុជាអនុវត្តរបបសេដ្ឋកិច្ចទីផ្សារសេរី ហើយសេដ្ឋកិច្ចជាតិ

នៅពឹងផ្អែកលើលំហូរមូលធនបរទេសនៅឡើយ ។ វិធានការទាំងនេះអាចបណ្ដាលឱ្យមានលំហូរចេញមូលធន និងការបង្កើតទីផ្សារងងឹតចរាចរណ៍រូបិយប័ណ្ណ ។ ដូច្នេះ លទ្ធផលនៃការប្រើវិធានការរដ្ឋបាលបង្ខិតបង្ខំ នឹងអាចនាំទៅរកការបាត់បង់លំនឹងម៉ាក្រូសេដ្ឋកិច្ច និងកំណើន ។ ដោយពិនិត្យឃើញបច្ច័យទាំងនេះហើយ ទើបរាជរដ្ឋាភិបាលបានអនុវត្តគោលនយោបាយលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលជាលំដាប់ ដោយផ្អែកលើយន្តការទីផ្សារ ដូចដែលសម្ដេចតេជោនាយករដ្ឋមន្ត្រីធ្លាប់បានលើកឡើងថា គ្រាប់បែកបើផ្ទុះគឺសម្លាប់មនុស្សមួយក្រុមតូច តែបើគ្រាប់បែកម៉ាក្រូសេដ្ឋកិច្ចផ្ទុះវិញ គឺនឹងប៉ះពាល់ដល់ប្រជាជនក្នុងប្រទេសទាំងមូល ។

យោងតាមការសិក្សាស្រាវជ្រាវរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ វិស័យហិរញ្ញវត្ថុត្រូវបានទទួលស្គាល់ថា បានដើរតួនាទីយ៉ាងសំខាន់ក្នុងការជំរុញការប្រើប្រាស់រូបិយវត្ថុជាតិ ជាពិសេសតាមរយៈការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងទីផ្សារហិរញ្ញវត្ថុ ដូចជាទីផ្សារប្ដូរប្រាក់ ទីផ្សារអន្តរធនាគារនិងទីផ្សាររូបិយវត្ថុ ទីផ្សារទុន និងទីផ្សារបំណុល ជាដើម ។ បទពិសោធន៍របស់ប្រទេសប៉ារ៉ាហ្គាយ បូលីវី ប៉េរូ អ៊ុយរ៉ាហ្គាយ និងអ៊ីស្រាអែល បង្ហាញថា ការអភិវឌ្ឍទីផ្សារមូលធននិងទីផ្សារបំណុលជារូបិយវត្ថុជាតិ បានជំរុញការបង្កើតឧបករណ៍ហិរញ្ញវត្ថុជារូបិយវត្ថុជាតិ និងបានបង្កើនតម្រូវការរូបិយវត្ថុក្នុងសេដ្ឋកិច្ច ដែលជាលទ្ធផលបានរួមចំណែកបន្ថយកម្រិតដុល្លារូបនីយកម្មជាលំដាប់ ។

ចំណែកឯបទពិសោធន៍របស់ប្រទេសឡាវ ប៉ូឡូញ និងទួគី បានបង្ហាញថា ការអភិវឌ្ឍទីផ្សារប្ដូរប្រាក់បានរួមចំណែកក្នុងការជំរុញការប្រើប្រាស់រូបិយវត្ថុជាតិ ជាពិសេស តាមរយៈការសម្រួលលំហូរចរាចររូបិយវត្ថុ ការកំណត់បរិមាណតម្រូវការនិងផ្គត់ផ្គង់រូបិយវត្ថុសមស្រប និងការរក្សាបានស្ថិរភាពអត្រាប្ដូរប្រាក់ ក៏ដូចជាការគ្រប់គ្រងគោលនយោបាយអត្រាប្ដូរប្រាក់ប្រកបដោយប្រសិទ្ធភាព ។ ការណ៍នេះនឹងបង្កើនជំនឿទុកចិត្តរបស់សាធារណជនមកលើអាជ្ញាធររូបិយវត្ថុហើយការប្រើប្រាស់រូបិយវត្ថុជាតិសម្រាប់ការសន្សំ និងសម្រាប់ការទូទាត់នឹងមានការកើនឡើងជាលំដាប់ ។ ទន្ទឹមនេះដែរ ការបង្កើតធានារ៉ាប់រងលើប្រាក់បញ្ញើជារូបិយវត្ថុជាតិ ក៏ត្រូវបានបង្ហាញថា បានលើកកម្ពស់ជំនឿទុកចិត្តសាធារណជនលើប្រព័ន្ធធនាគារ និងលើកទឹកចិត្តដល់ការដាក់ប្រាក់បញ្ញើជារូបិយវត្ថុជាតិផងដែរ ។